# មេរៀនទី ១០៩:
# យ៉ូសែបនាំគ្រួសាររបស់គាត់ទៅកន្លែងមានសុវត្ថិភាពនៅស្រុកអេស៊ីព្ទ
## ម៉ាថាយ ២:១៣-២៣

**គោលបំណង៖** ព្រះធ្វើការនៅក្នុងជីវិតយើង។

**ខគម្ពីរចងចាំ៖** ណាហ៊ុម ១:៧ *"ព្រះយេហូវ៉ាទ្រង់ល្អ ទ្រង់ជាទីពឹងមាំមួននៅគ្រាលំបាក ក៏ស្គាល់អស់អ្នកដែលយកទ្រង់ជាទីពឹងផ្អែក។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ដំណើរជីវិតរបស់ព្រះយេស៊ូវបានបង្ហាញយើងថា ព្រះតែងតែស្មោះត្រង់ដើម្បីដឹកនាំយើងតាមផែនការ និងការសន្យារបស់ទ្រង់ ។ សូមអាន **ម៉ាថាយ ២:១៣-២៣** ឡើងវិញ។ បន្ទាប់មកសូមគិតអំពីពេលវេលាមួយដែលព្រះបានដឹកនាំអ្នកឆ្លងកាត់ស្ថានភាពដ៏លំបាកមួយ។ តើវាមានឥទ្ធិពលយ៉ាងណាទៅលើរបៀបរស់នៅរបស់អ្នកក្រោយមក? ឃើញអត់ នោះជារឿងដ៏អស្ចារ្យអំពីព្រះ។ យើងភ័យខ្លាច មិនទុកចិត្តទ្រង់ ប៉ុន្តែយើងបានធ្វើវាហើយព្រះអង្គបានបង្ហាញយើងថា ទ្រង់មានផែនការល្អឥតខ្ចោះ ហើយនឹងផ្តល់រង្វាន់ដល់យើងសម្រាប់ការទុកចិត្តលើព្រះអង្គ។ វាជាអ្វីដែលយើងមិនគួរភ្លេចនោះឡើយ។

**ចំរៀង៖** ១. ខ្ញុំទុកចិត្តដល់ព្រះយេស៊ូវ ២. ព្រះអម្ចាស់តាមការពារ ៣. ទ្រង់មិនដែលខាន

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត** « **រកមកឲ្យខ្ញុំ**......»




**សម្ភារៈដែលត្រូវការ៖** ក្រដាសដែលមានសរសេរនូវអ្វីដែលគ្រូចង់ឲ្យសិស្សយកមកឲ្យគាត់
១. ចែកកុមារជា ២ ឬ ៣ក្រុម
២. គ្រូឈរនៅកណ្តាលថ្នាក់រៀន ហើយស្រែកនូវអ្វីដែលគាត់បានសរសេរនៅក្នុងក្រដាស (ថ្ម៥ដុំ, ស្បែកជើង៣គូរ, ស្លឹកស្វាយ ១០សន្លឹក, មួក ២។ល។)
៣. កុមារទាំងអស់ត្រូវព្យាយាមរត់ទៅស្វែងរករបស់ដែលគ្រូបានប្រាប់ឲ្យរកនោះ ហើយយកវាមកឲ្យគ្រូ។
៤. ក្រុមណាដែលអាចយករបស់នោះមកឲ្យគ្រូបានមុនគេ ក្រុមនោះនឹងទទួលបាន១ពិន្ទុ។
៥. ក្រុមណាដែលមានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះល្បែងនេះ។
៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពួកគេបានធ្វើការជាមួយគ្នាយ៉ាងឆាប់រហ័ស ដើម្បីឈ្នះល្បែងនេះ។ យ៉ូសែបបានធ្វើការយ៉ាងលឿន ដើម្បីនាំគ្រួសាររបស់គាត់ទៅកន្លែងដែលមានសុវត្ថិភាព ដើម្បីការពារដល់ព្រះបុត្រតូច។

## ៤. ការណែនាំមេរៀន

តើមានអ្វីដែលធ្វើឲ្យអ្នកខ្វាយខ្វល់ពីវាដែរឬទេ? តើអ្នកបារម្ភពីក្រុមគ្រួសាររបស់អ្នកឬ? ពីមិត្តភក្តិរបស់អ្នកឬ? ពីការសិក្សា ឬក៏ថ្ងៃអនាគតរបស់អ្នកឬ? តើអ្នកព្យាយាមស្វែងយល់ពីជីវិតរបស់អ្នកដោយខ្លួនឯងឬ? ដំណឹងល្អគឺថា ព្រះចង់ជួយអ្នក! ព្រះមិនចង់ឱ្យអ្នកទទួលបន្ទុកដោយការព្រួយបារម្ភនោះទេ។ ព្រះចង់ជួយអ្នក និងណែនាំអ្នក។ ព្រះនឹងមិនទៅណាឬចាកចេញពីយើងឡើយ ហើយព្រះនឹងជួយយើងគ្រប់ទាំងផ្លូវ។ ព្រះធ្វើការនៅក្នុងជីវិតរបស់យើង។ ថ្ងៃនេះយើងនឹងរៀនអំពីរបៀបដែលព្រះបានធ្វើការក្នុងជីវិតរបស់យ៉ូសែបនិងម៉ារា ដើម្បីសង្គ្រោះទារកយេស៊ូវ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ស្តេចហេរ៉ូឌជាស្តេចនៃសាសន៍អ៊ីស្រាអែលមិនសប្បាយចិត្តនោះទេនៅពេលដែលឮថា បុត្រតូចនឹងប្រសូត្រនៅបេថ្លេហិម ហើយជាម្នាក់ដែលនឹងធ្វើជាស្តេចលើអស់ទាំងស្តេច នៅពេលដែលទ្រង់ធំឡើងនោះ។ នៅពេលដែលស្តេចហេរ៉ូឌបានដឹងថា ហោរា៣នាក់មិនមកប្រាប់គាត់វិញអំពីដំណឹងបុត្រតូចនៅឯណានោះ គាត់បានសម្រេចចិត្តចាត់វិធានការមួយ។ ដើម្បីប្រាកដថា នឹងសម្លាប់អនាគតស្តេចថ្មីនេះ ទ្រង់បានបញ្ជាឱ្យសម្លាប់ទារកដែលមានអាយុក្រោម២ឆ្នាំនៅក្រុងបេថ្លេហិមទាំងអស់! ស្តេចហេរ៉ូឌបានតាំងចិត្តសម្លាប់ស្តេចនាពេលអនាគត ដែលជាព្រះមេស្ស៊ី។

ប៉ុន្តែព្រះទ្រង់ជ្រាបដឹងគ្រប់យ៉ាង។ ព្រះដឹងថាស្តេចហេរ៉ូឌ នឹងព្យាយាមសម្លាប់ព្រះយេស៊ូវ ដូច្នេះទ្រង់ក៏បានបង្ហាញខ្លួននៅក្នុងសុបិនរបស់យ៉ូសែប ហើយបានប្រាប់យ៉ូសែបឲ្យនាំក្រុមគ្រួសាររបស់គាត់ទៅអេស៊ីព្ទ ដែលជាកន្លែងដែលអាចជួយឲ្យព្រះយេស៊ូវមានសុវត្ថិភាពបាន។ យ៉ូសែបមិនបានដឹងពីមូលហេតុដែលគាត់ត្រូវផ្លាស់ទីទៅប្រទេសដទៃគឺអេស៊ីព្ទនោះទេ ប៉ុន្តែយ៉ូសែបទុកចិត្តព្រះ។ យ៉ូសែបបានដឹងថា ព្រះតែងតែធ្វើការក្នុងជីវិតរបស់គាត់ ហើយមិនដែលធ្វើឲ្យគាត់បរាជ័យឡើយ។ ដូច្នេះ ហើយទើបយ៉ូសែបបានស្តាប់បង្គាប់ព្រះភ្លាមៗនោះ។

បន្ទាប់ពីស្តេចហេរ៉ូឌស្លាប់ទៅ ទេវតានៃព្រះបានលេចមកចំពោះយ៉ូសែប ហើយបានប្រាប់គាត់ឲ្យចាកចេញពីអេស៊ីព្ទត្រឡប់ទៅអ៊ីស្រាអែលវិញ។ ហើយជាថ្មីម្តងទៀតយ៉ូសែបមិនយល់អ្វីទាំងអស់ ប៉ុន្តែគាត់បានទុកចិត្តព្រះ និងស្តាប់បង្គាប់ទ្រង់។ ពេលយ៉ូសែប និងម៉ារាត្រឡប់ទៅស្រុកអ៊ីស្រាអែលវិញ ពួកគេមិនមានអារម្មណ៍ថាបានត្រឡប់ទៅក្រុងបេថ្លេហិមជាស្រុកកំណើតរបស់ពួកគេវិញនោះទេ ដោយសារពួកគេភ័យខ្លាចនឹងកូនប្រុសរបស់ស្តេចហេរ៉ូឌ គឺអើខេឡោស។ ដូច្នេះពួកគេបានផ្លាស់ទៅស្រុកកាលីឡេ ហើយរស់នៅក្នុងក្រុងមួយឈ្មោះណាសារ៉ែត ជាកន្លែងដែលព្រះយេស៊ូវអាចធំធាត់ដោយសុវត្ថិភាព។

ជីវិតរបស់យ៉ូសែបពិតជាមិនងាយស្រួលនោះទេ។ ប៉ុន្តែ យ៉ូសែបតែងតែទុកចិត្តព្រះហើយអនុញ្ញាតឲ្យព្រះធ្វើការក្នុងជីវិតរបស់គាត់។ ពេលគាត់មានការព្រួយបារម្ភ ឬបញ្ហាគាត់ទុកចិត្តលើការណែនាំរបស់ព្រះ ហើយស្តាប់តាម។ ដូចគ្នានេះ ព្រះក៏ធ្វើការក្នុងជីវិតយើងដែរ!ទ្រង់តែងតែនៅជាមួយយើង ដូចជាទ្រង់តែងតែនៅជាមួយព្រះយេស៊ូវដែរ។ ព្រះយកចិត្តទុកដាក់ចំពោះយើងខ្លាំងណាស់ ទើបទ្រង់ជួយយើងហើយដឹកនាំយើងគ្រប់ទាំងផ្លូវ! ព្រះគម្ពីរប្រាប់យើងថា ព្រះធ្វើការក្នុងជីវិតរបស់យើង ហើយនឹងតែងតែនាំមកនូវអ្វីដែលល្អៗសម្រាប់យើង។

យើងអាចប្រាកដថាព្រះនៅជាមួយយើងជានិច្ច។ ទ្រង់តែងតែចាប់អារម្មណ៍នឹងអ្វីដែលកើតឡើងចំពោះយើង ហើយព្រះអង្គនឹងធ្វើការនៅក្នុងជីវិតរបស់យើងជានិច្ច!

**៦. សំនួរពិភាក្សា**

១. តើស្តេចហេរ៉ូឌបានធ្វើអ្វីនៅពេលដែលហោរាទាំងបីមិនបានត្រឡប់មកវិញ ហើយប្រាប់គាត់ថាបុត្រតូចនៅឯណានោះ? *ទ្រង់បានបញ្ជាឱ្យសម្លាប់ទារកដែលមានអាយុក្រោម២ឆ្នាំនៅក្រុងបេថ្លេហិមទាំងអស់!*

២. តើព្រះបានធ្វើការនៅក្នុងជីវិតរបស់យ៉ូសែបដោយរបៀបណាដើម្បីការពារបុត្រតូចនោះ? *ព្រះបានប្រាប់យ៉ូសែបឲ្យនាំម៉ារានិងបុត្រតូចទៅអេស៊ីព្ទមុនពេលហេរ៉ូឌបញ្ជាឲ្យគេសម្លាប់ក្មេងដែលមានអាយុក្រោម២ឆ្នាំទាំងអស់*

៣. តើព្រះបានធ្វើការយ៉ាងដូចម្តេចក្នុងជីវិតរបស់អ្នក? *ទុកឲ្យកុមារជាអ្នកឆ្លើយ*

**៧. ល្បែងកំសាន្ត** «ដណ្តើមហើយការពារ»

**សម្ភារៈដែលត្រូវការ៖** ហ្វឺត ស្កុត បាល់តូច កូឡ័រ តុក្កតា ដបទឹក កៃវជ័រ កៅអី៣ ឬ៤ កៅអីក៏បាន

១. ចែកកុមារជា ៣ ឬ ៤ក្រុម




២. ឲ្យកុមារក្នុងក្រុមឈរ ដោយផ្អែកលើអាយុ (ឬតាមមាឌ) ដើម្បីឲ្យការលេងស្មើភាពគ្នា ហើយដាក់កៅអីមួយនៅពីមុខក្រុមនីមួយៗ។

៣. ដាក់លេងរៀងឲ្យកុមារគ្រប់ៗគ្នា។

៤. គ្រូនឹងដាក់របស់ទាំងអស់នៅកណ្តាលថ្នាក់រៀន។

៥. នៅពេលដែលគ្រូហៅលេខណាមួយ កុមារដែលឮលេខរៀងរបស់ខ្លួនមកពីក្រុមទាំងអស់ត្រូវរត់ទៅរក ហើយយករបស់ដែលដាក់នៅកណ្តាលថ្នាក់នោះឲ្យបាន៣មុខ។ ប៉ុន្តែពួកគេអាចយកបានម្តងតែមួយប៉ុណ្ណោះ ហើយយកវាមកដាក់នៅលើកៅអីរបស់ពួកគេ ហើយរត់ទៅយកបន្តទៀត។ ប៉ុន្តែក្រុមផ្សេងអាចលួចរបស់ដែលនៅលើកៅអីនោះបាន។ ដូច្នេះ កុមារត្រូវតែរហ័សរហួន!

៦.កុមារណាដែលអាចយករបស់៣យ៉ាងមកដាក់នៅលើកៅអីរបស់ខ្លួនបានមុនគេក្រុមគេនឹងទទួលបានមួយពិន្ទុ

៧. យករបស់របរដាក់នៅកណ្តាលទាំងអស់វិញ រហូតដល់កុមារគ្រប់គ្នាបានលេងគ្រប់ៗគ្នា។

៨. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ដូចជាកុមារទាំងអស់ព្យាយាមការពាររបស់ទាំងបីនោះ យ៉ូសែបបានការពារដល់ព្រះបុត្រតូចពីស្តេចហេរ៉ូឌ។ យ៉ូសែបអាចធ្វើការនេះបានដោយសារគាត់ទុកចិត្តលើព្រះដែលធ្វើការនៅក្នុងជីវិតរបស់យើង។

**៨. ខគម្ពីរចងចាំ** ណាហ៊ុម ១:៧

**៩. ហត្ថកម្ម** ផាត់ពណ៌ - «យ៉ូសែបនាំគ្រួសាររបស់គាត់ទៅកន្លែងមានសុវត្ថិភាពនៅស្រុកអេស៊ីព្ទ»

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

## យ៉ូសែបនាំគ្រួសាររបស់គាត់ទៅកន្លែងមានសុវត្ថិភាពនៅស្រុកអេស៊ីព្ទ



សូមសរសេរខគម្ពីរចងចាំ: